Newleaf Communities

# តើមានអ្វីកើតឡើងពេលណាខ្ញុំរាយការណ៍អំពីបញ្ហាជួសជុលផ្ទះរបស់ខ្ញុំ?

សហគមន៍ Newleaf ផ្តល់នូវបទដ្ឋានជួសជុលដែលមានកិរិតខ្ពស់សំរាប់អ្នកជួលទីលំនៅ។

ពេលណាអ្នកជួលទីលំនៅរាយការណ៍អំពីបញ្ហាណាមួយ បញ្ហានោះត្រូវបានផ្តល់អាទិភាពដោយយោងទៅលើប្រភេទនៃការជួសជុលដែលតម្រូវ។ បន្ទាប់ពីគេបានដាក់ទៅតាមប្រភេទហើយ ការជួសជុលនោះត្រូវតែបានគេរៀបំ ហើយជួសជុលក្នុងរយៈពេលដ៏ជាក់លាក់។

តារាងខាងក្រោមនេះផ្តល់នូវឧទាហរណ៍ខ្លះៗអំពីបញ្ហាទាំងឡាយ និងពេលម៉ោងដែលនឹងត្រូវការដើម្បីជួសជុល។

| ប្រភេទ | បញ្ហា | ឧទាហរណ៍ | ពេលម៉ោងឆ្លើយតប |
|---|---|---|---|
| **បន្ទាន់** | ការជួសជុលណាមួយដែលអាចធ្វើឲ្យលំនៅដ្ឋានពុំមានសុវត្ថិភាពសំរាប់រស់នៅ ប្រសិនបើពុំចាត់វិធានការឲ្យបានភ្លាមៗទេ។ | ការដាច់ភ្លើង ការធ្លាយបំពង់ទឹក ការស្ទះ ឬលេចលូទឹកសំអុយ បង្អួចបែកបាក់ ការវាយបាក់បែក និងចូលលួចក្នុងផ្ទះ។ល។ | វិធានការបន្ទាន់។<br>ត្រូវធ្វើឡើងក្នុងរយៈពេលមួយម៉ោង ហើយកែតម្រូវ ឬធ្វើឲ្យមានសុវត្ថិភាពក្នុងរយៈពេល៤ម៉ោងបន្ទាប់ពីបានទទួលការហៅ។ |
| **អសុវត្ថិភាព** | ឧបត្តិហេតុដែលបណ្តាលឲ្យមានគំរាមកំហែងដល់សុខភាព ឬសុវត្ថិភាពអ្នកជួលទីលំនៅណាម្នាក់។ | ការដាច់ភ្លើងផ្នែកខ្លះ ចង្ក្រានដុតមិនធ្វើការ ប្រព័ន្ធទឹកក្តៅលេច ការខូចខាតដល់ការផ្គត់ផ្គង់ទឹក ឬធ្លាយក្បាលម៉ាស៊ីនទឹក ធ្លាយលូទឹកសំអុយនៅក្រោមដី។ | ឆ្លើយតប ហើយកែសម្រួលក្នុងរយៈពេល៤ម៉ោងបន្ទាប់ពីបានទទួលការហៅ។ |
| **ការខូចខាត** | ទាក់ទិននឹងការបាត់បង់ចលនា ឬគ្រឿងសំរួល។ | ការខូចខាតប្រព័ន្ធទឹកក្តៅ បង្គន់មិនបញ្ចេញទឹកត្រឹមត្រូវ ភ្លើងមិនឆេះ សោទ្វារមិនធ្វើការ និងបញ្ហាស្រដៀងគ្នានេះ។ | តម្រូវឲ្យមានការឆ្លើយតប ហើយកែតម្រូវឲ្យបានទាន់ម៉ោង៦យប់ បន្ទាប់ពីថ្ងៃធ្វើការក្រោយពីបានទទួលដំណឹង។ |
| **ការជួសជុល** | ការជួលជុលណាមួយដែលមិនគំរាមកំហែងដល់សុវត្ថិភាព ឬសុខភាពអ្នកជួលទីលំនៅណាម្នាក់។ | ការជួសជុលរបងផ្ទះ ប្រដាប់ដាក់ហាលខោអាវខូច ដាក់កាសទ្រនាប់ក្បាលម៉ាស៊ីនទឹកថ្មី។ល។ | ការឆ្លើយតបក្នុងរយៈពេល៥ថ្ងៃធ្វើការ ហើយកែសម្រួលក្នុងរយៈពេល២០ថ្ងៃធ្វើការ។ |

PO BOX 151 Bonnyrigg LPO NSW 2177
ការិយាល័យ: 1300 137 265 ទូរសារ: 9616 9100
info@newleafcommunitiess.com.au

Newleaf Communities

# សន្លឹកព័ត៌មានៈ
# កិច្ចបំរើ និងការជួសជុល

## តើការជួសជុលធម្មតាណាខ្លះដែលខ្ញុំអាចរំពឹងថានឹងបានទទួលសំរាប់ផ្ទះរបស់ខ្ញុំ?

ផ្ទះទាំងឡាយត្រូវបានមើលថែ ដែលក្រសួងទីលំនៅរដ្ឋញូវសោវែល ហៅថា "ការផ្លាស់ប្តូរធម្មតា"។ នេះត្រូវបានឲ្យអត្ថន័យថាៈ ស្អាត សុវត្ថិភាព ហើយដែលអាចរស់នៅបាន។

ក្នុងរយៈពេល១៥ឆ្នាំខាងមុខនេះ ផ្ទះទាំងឡាយនៅ Bonnyrigg នឹងត្រូវគេរុះរើចោល ហើយសាងសង់ឡើងវិញជាមួយនឹងផ្ទះថ្មីៗ។ នេះមានន័យថា ការធ្វើឲ្យប្រសើរឡើងនឹងត្រូវរក្សាឲ្យមានតិចបំផុត ដើម្បីប្រាកដឲ្យបានច្បាស់ថា ថវិកាសាធារណៈត្រូវបានយកមកប្រើប្រាស់ដោយសមស្រប។

នៅគ្រប់ករណីទាំងអស់ យើងនឹងវាយតម្លៃឲ្យបានសមរម្យចំពោះការជួសជុលក្នុងពេលកំពុងផ្លាស់ប្តូរណាមួយ ហើយបំពេញឲ្យបានអស់ពីសមត្ថភាពរបស់យើង ដើម្បីបំពេញទៅលើសេចក្តីត្រូវការរបស់អ្នកជួលទីលំនៅ។

ឧទាហរណ៍ យើងអាចជួសជុលប៉ះកំរាល ជាជាងដាក់កំរាលថ្មី ឬលាបថ្នាំនៅតាមផ្នែកនៃជញ្ជាំង ជាជាងលាបថ្នាំពេញជញ្ជាំងទាំងមូល។ បន្ទប់ទឹក និងចង្ក្រានដាំស្លអាចត្រូវជួសជុលដោយផ្នែកៗ ជាជាងដាក់ថ្មី។ ពេលណាពុំអាចរកបានវត្ថុដូចគ្នាទេ កន្លែងដែលជួសជុលប៉ះអាចមានពណ៌ គំរូ ឬគំរោង ឬផ្នែកខាងក្រៅខុសគ្នាទៅនឹងសភាពដែលកំពុងមាន។

## ការជួសជុលដែលដល់ពេលធ្វើឡើងវិញ

យើងមានកម្មវិធីជួសជុលដែលដល់ពេលធ្វើឡើងវិញ ដែលគ្រឿងសង្ហារឹមត្រូវការដាក់ប្តូរថ្មីដោយព្រោះតែវាចាស់រិចរឹល។ ឧទាហរណ៍មានរួមទាំងចង្ក្រានដុត ប្រព័ន្ធទឹកក្តៅ ចង្ក្រានដាំស្ល បន្ទប់ទឹក និងប្រដាប់ដាក់ហាលខោអាវ។

ផ្ទះនីមួយៗត្រូវបានឆែកមើលជារៀងរាល់ឆ្នាំ ដើម្បីកំណត់ទៅលើការជួសជុលដែលតម្រូវ។ បន្ទាប់មក កម្មវិធីជួសជុលត្រូវបានបង្កើតឲ្យមានឡើង ហើយរៀបចំឲ្យបានទាន់ពេលជារៀងរាល់ឆ្នាំ។

## សូមប្រាប់ឲ្យយើងបានដឹងប្រសិនបើផ្ទះរបស់លោកអ្នកមានបញ្ហាណាមួយ

ដើម្បីរាយការណ៍អំពីបញ្ហាណាមួយ សូមអញ្ជើញមកហាងរបស់យើងនៅផ្សារធំ Shop 38 Bonnyrigg Plaza ចាប់ពីម៉ោង៩ព្រឹក ទៅម៉ោង៥ល្ងាច ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ។

ឬ

ទូរស័ព្ទមកអ្នកទទួលភ្ញៀវដ៏រាក់ទាក់របស់យើង ពីម៉ោង៩ព្រឹក ទៅម៉ោង៥ល្ងាច ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ។ លេខទូរស័ព្ទអ្នកទទួលភ្ញៀវរបស់យើងគឺ **1300 137 265**។ លេខនេះក៏មានផ្តល់ផងដែរក្រោយម៉ោងធ្វើការ សំរាប់ការជួសជុលបន្ទាន់ណាមួយ។

លោកអ្នកនឹងបានទទួលលេខយោង និងពេលម៉ោងជួសជុលចំពោះសំណើរជួសជុលណាមួយដែលលោកអ្នកបានធ្វើឡើង។

ប្រសិនបើលោកអ្នកមិននិយាយភាសាអង់គ្លេសទេ សូមទូរស័ព្ទមកយើងលេខ **1300 137 265**។ សូមប្រាប់យើងនូវឈ្មោះ លេខទូរស័ព្ទ និងភាសាដែលលោកអ្នកនិយាយ។ យើងនឹងទូរស័ព្ទទៅលោកអ្នកវិញជាមួយអ្នកបកប្រែភាសា។

អ្នកជួលទីលំនៅដែលមានពិការភាពលើការស្តាប់ឮ អាចទាក់ទងយើងតាមរយៈ TTY 1800 628 310។

**PO BOX 151 Bonnyrigg LPO NSW 2177**
ការិយាល័យៈ **1300 137 265** ទូរសារៈ **9616 9100**
**info@newleafcommunitiess.com.au**